ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលជួបសម្តែងការគួរសមរបស់ប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍ និងផ្តល់អនុសាសន៍អំពីប្រព័ន្ធពន្ធដារកម្ពុជា និងកំណែទម្រង់រដ្ឋបាលសារពើពន្ធ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នារសៀលថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួបសម្តែងការគួរសមរបស់ប្រតិភូ នាវាយុវជនអាស៊ីអាគ្នេយ៍ចំនួន ៣៣ នាក់ និងផ្តល់អនុសាសន៍អំពីប្រព័ន្ធពន្ធដារកម្ពុជា និងកំណែទម្រង់រដ្ឋបាលសារពើពន្ធ។

ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល បានបញ្ជាក់ថា ការធ្វើកំណែទម្រង់ របស់អគ្គនាយកដ្ឋានពន្ធដារ គឺធ្វើឡើងប្រកបដោយចក្ខុវិស័យ បេសកកម្ម និងគោលដៅដ៏ច្បាស់លាស់របស់អគ្គនាយកដ្ឋានពន្ធដារ ស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ដ៏មុតស្រួច របស់រាជរដ្ឋាភិបាល តាមរយៈការអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ ការងារកែទម្រង់រដ្ឋបាលសារពើពន្ធ ជានិច្ចជាកាលតែងតែអនុវត្ត

យ៉ាងខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់ ស្របតាមឆន្ទៈគោលនយោបាយកំណែទម្រង់ របស់រាជរដ្ឋាភិបាលអាណត្តិទី ៥ ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ដោយមិនមានការដំឡើងអត្រាពន្ធ ឬបង្កើតប្រភេទពន្ធថ្មីឡើយ មានតែពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមានតែប៉ុណ្ណោះ ប្រមូលឱ្យអស់លទ្ធភាពនូវសក្តានុពល និងធានាឱ្យបាននូវភាពងាយស្រួលសមធម៌ និងយុត្តិធម៌ ដើម្បីបង្កើតនូវបរិយាកាសប្រកួតប្រជែងដោយស្មើភាពគ្នា ក្នុងចំណោមអ្នកជាប់ពន្ធទាំងអស់។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានសង្កត់ធ្ងន់ថាកំណែទម្រង់ទាំងឡាយគឺ សម្រេចឱ្យបាននូវមូលដ្ឋាននៃភាពរឹងមាំ នៃថវិកា និងសេដ្ឋកិច្ចជាតិ ដើម្បីអនាគតរបស់ប្រទេសជាតិ អនាគតរបស់យុវជន ដែលជាសសរទ្រូងរបស់ប្រទេសជាតិ។ គួរជាទីមោទនលទ្ធផលប្រមូលចំណូលពន្ធ គឺឆ្លុះបញ្ចាំងអំពីលទ្ធផលនៃកំណើននៃកម្រិតអនុលោមភាពពន្ធដែលទទួល បានយ៉ាងប្រសើរជាបន្តបន្ទាប់ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ចាប់តាំងពីឆ្នាំ ២០១២ គឺតែងតែសម្រេចបានលើសផែនការ ហើយការប្រមូលចំណូលពន្ធ បានកើនឡើងជាមធ្យមប្រមាណ ២០% ក្នុងមួយឆ្នាំ ដែលជាក់ស្តែងបានកើនប្រមាណពី ៧៣៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១២ រហូតទទួលបានប្រមាណជាង ១,៤ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦។ ដោយឡែកគិតត្រឹម ៨ខែ ដើមឆ្នាំ ២០១៧ សម្រេចបាន ៥,៦៥៧ពាន់លានរៀល ស្មើនឹងប្រមាណជា ១,៤១៤.៤៣លានដុល្លាអាមេរិក ត្រូវជា ៨២.៤៣% នៃផែនការកំណត់ដោយច្បាប់។

ឯកឧត្តមប្រតិភូ បានចែករំលែកបទពិសោធន៍ថា ការអនុវត្តកំណែទម្រង់ ជៀសមិនផុតនូវផលប៉ះពាល់គ្រាន់តែតិច ឬច្រើន ជាពិសេស ការផ្លាស់ប្តូរផ្នត់គំនិត និងវប្បធម៌ការងារពី "មន្ត្រីពន្ធដារ ជាអ្នកត្រួតត្រាអ្នកជាប់ពន្ធ ទៅជាអ្នកផ្តល់សេវា" និង ការប្រឈមនៃ "សត្រូវនៃការកែទម្រង់ គឺអ្នកមិនចង់កែទម្រង់"។ ក្នុងភាពជាអ្នកដឹកនាំស្ថាប័ន ដើម្បីឈានទៅទទួលជោគជ័យនៃការងារកំណែទម្រង់ត្រូវការឆន្ទៈខ្ពស់ (Willingness) ការតាំងចិត្តពុះពារមិនរាថយ (Commitment) ចំណេះដឹង (Knowledge) ភាពជឿជាក់ (Confidence) ការបំពេញការងារប្រកបប្រតិសកម្ម (Proactive) និងគំនិតផ្តួចផ្តើម (Initiative)។

ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានជំរុញ និងលើកទឹកចិត្តប្អូនៗ ប្រតិភូនារាយុវជនអាស៊ីអាគ្នេយ៍ ចំនួន ៣៣ នាក់ ផ្សព្វផ្សាយចែករំលែកបន្តចំណេះដឹង និងបទពិសោធន៍ការងារ ពាក់ព័ន្ធនឹងវិស័យពន្ធដារ និងក្នុងន័យពង្រឹង និងបញ្ជ្រាបវប្បធម៌នៃការបង់ពន្ធនៅកម្ពុជា ឱ្យបានកាន់តែជ្រួតជ្រាបដល់មជ្ឈដ្ឋានអ្នកជាប់ពន្ធ ក៏ដូចជាមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធទាំងអស់។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ក៏បានឧបត្ថម្ភថវិកា ជូនប្រតិភូនារាយុវជនអាស៊ីអាគ្នេយ៍ទាំង ៣៣ នាក់។



© *រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ*



© *រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ*



© *រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ*

ក្រោយពីបានស្តាប់នូវរបាយការណ៍ និងអនុសាសន៍របស់ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ប្រធានប្រតិភូនារាយុវជនអាស៊ីអាគ្នេយ៍បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងបង្ហាញពីចំណាប់អារម្មណ៍ ចំពោះលទ្ធផលកំណែទម្រង់នេះ ហើយរំពឹងថា កំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារនឹងជាគំរូមួយសម្រាប់គ្រឹះស្ថានសាធារណផ្សេងៗទៀត ហើយប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍ នឹងផ្សព្វផ្សាយនូវលទ្ធផលកំណែទម្រង់ ប្រកបដោយមោទនភាព ជូនដល់សាធារណៈជនជាតិ និងអន្តរជាតិ ជាពិសេសក្នុងកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ ពីថ្ងៃទី២៣ ខែតុលា ដល់ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ខាងមុខនេះ។

ជាកិច្ចបញ្ចប់ ប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍ បានជូនជាលិខិតថ្លែងអំណរគុណ ចំពោះឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ដែលបានចំណាយពេលវេលាក្នុងការទទួលជួប ផ្តល់អនុសាសន៍ និងថវិកា ឧបត្ថម្ភដល់ប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍ ទាំង ៣៣ នាក់៕


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ